ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**
សាលក្រមរដ្ឋប្បវេណីលេខ **១០ "ខ"**
ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ នៅសាលសវនាការជាសាធារណៈនៃសាលាដំបូងខេត្តកណ្តាល លើសំណុំរឿងរដ្ឋប្បវេណីលេខៈ ៣៩២ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ ២០២០ ដោយមានសមាសភាពដូចខាងក្រោម៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] អនុប្រធានសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើមចោទឈ្មោះ [redacted] រ័ត្ន ([redacted] ROTH) ភេទស្រី អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន[redacted]។

មានលោក [redacted] លោក [redacted] អត្តលេខ ១៨៣០T និងលោក [redacted] អត្តលេខ ១៨៥២T ជាអ្នកតំណាងដោយអាណត្តិ។

ចុងចម្លើយឈ្មោះ [redacted] អន់គុន [redacted] EONGUN) ភេទប្រុស ជនជាតិកូរ៉េ ទីលំនៅ[redacted]។

### អង្គហេតុ និងចំណុចវិវាទ

១-ការទាមទាររបស់ដើមចោទ

ដើមចោទទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារ៖

-ទទួលស្គាល់លិខិតបញ្ជាក់តាមសំណុំរឿងលេខ ២០១៨ ហ្វូហ្សប់ ៤៥៨ ស្នើសុំបញ្ជាក់ការព្រមព្រៀងលែងលះ ចុះថ្ងៃទី២៨ ខែ សីហា ឆ្នាំ២០១៨ របស់តុលាការគ្រួសារសុកដេឆន់ ខេត្តឆន់អាន របស់ប្រទេសកូរ៉េ ។

២-អង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ដើមចោទ



Scanned with CamScanner

ដើមចោទបានប្ដឹងថា ខ្លួននិងចុងចម្លើយឈ្មោះ [redacted] អន់គុន បានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណីទំនៀមទំលាប់ខ្មែរ នៅប្រទេសកម្ពុជា ក្រោយរៀបការរួចពួកខ្លួនក៏បានចាកចេញទៅរស់នៅប្រទេសកូរ៉េ តែការរស់នៅចេះតែមិនចុះសម្រុងនឹងគ្នា ជាហេតុធ្វើអោយរស់មនោសញ្ចេតនានឹងគ្នាតទៅទៀត ទើបខ្លួន និងឈ្មោះ [redacted] អន់គុន បានដាក់ពាក្យលែងលះនៅតុលាការនៃប្រទេសកូរ៉េ ហើយតុលាការប្រទេសកូរ៉េទទួលស្គាល់ និងចេញលិខិតបញ្ជាក់តាមសំណុំរឿងលេខ ២០១៨ ហូហ្សប់ ៤៥៨ ស្នើសុំបញ្ជាក់ការព្រមព្រៀងលែងលះ ហើយដែរ។ នៅប្រទេសកូរ៉េពេលភាគីលែងលះរួចហើយ គឺតុលាការរបស់ប្រទេសកូរ៉េចេញលិខិតបញ្ជាក់ការព្រមព្រៀងលែងលះ ដែលបញ្ជាក់ថាបានលែងលះគ្នាស្ថាពររួចហើយ។

៣.ការអះអាងរបស់ភាគី

ក-អ្នកតំណាងដោយអាណត្តិអោយដើមចោទឈ្មោះ [redacted] រ័ត្ន មានលោក [redacted] លោក [redacted] និងលោក [redacted] ជាអ្នកតំណាងដោយអាណត្តិ អះអាងដូចក្នុងចំណុចទី១ (ការទាមទាររបស់ដើមចោទ) និងទី២ (អង្គហេតុ ដែលជាមូលហេតុនៃការទាមទារ)ខាងលើ និងសុំបន្ថែមថា នៅប្រទេសកូរ៉េពេលភាគីលែងលះរួចហើយ គឺតុលាការរបស់ប្រទេសកូរ៉េចេញលិខិតបញ្ជាក់ការព្រមព្រៀងលែងលះ ដែលបញ្ជាក់ថាបាន លែងលះគ្នាស្ថាពររួចហើយ។

ខ-ចុងចម្លើយឈ្មោះ [redacted] អន់គុន ([redacted] EONGUN) អវត្តមាន។

៤.អំពីភស្តុតាង

-បានឃើញ លិខិតបញ្ជាក់តាមសំណុំរឿងលេខ ២០១៨ ហូហ្សប់ ៤៥៨ ស្នើសុំបញ្ជាក់ការព្រមព្រៀងលែងលះរបស់តុលាការគ្រួសារស្រុកដេចន់ ខេត្តឆន់អាន របស់តុលាការក្រុងអាសាន់ស៊ី។

៥-ក្នុងរឿងនេះ៖ ពុំមានចំណុចវិវាទទេ។

## សំអាងហេតុ

ឆ្លងតាមកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖

១-តាមការអះអាងរបស់អ្នកតំណាងដោយអាណត្តិលោក [redacted] លោក [redacted] និងលោក [redacted] ឃើញថា ដើមចោទឈ្មោះ [redacted] រ័ត្ន ជនជាតិខ្មែរ បានរៀបអាពាហ៍ពិពាហ៍និងឈ្មោះ [redacted] អន់គុន [redacted] EONGUN) ជនជាតិកូរ៉េ ជាមួយគ្នាត្រឹមត្រូវ។ ការរស់នៅជាមួយគ្នាចេះតែ រកាំរកូសជារៀងរាល់ថ្ងៃ ដើមចោទនិងចុងចម្លើយក៏បានព្រមព្រៀងលែងលះ ដោយបានដាក់ពាក្យទៅតុលាការនៃប្រទេសកូរ៉េ ហើយតុលាការចេញដីកាលេខ ៤៥៨ ជាលិខិតបញ្ជាក់ការព្រមព្រៀងលែងលះគ្នារបស់តុលាការស្រុកដេឆន់ ខេត្តចន់អាន តុលាការក្រុងអាសាន់ស៊ី របស់ប្រទេសកូរ៉េ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ គឺបញ្ជាក់ថាបានចូលស្ថាពររួចហើយ។

-តាមការអះអាងរបស់អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ មានភស្តុតាងគ្រប់គ្រាន់ អាចអោយតុលាការទទួលស្គាល់បាន។



Scanned with CamScanner

- យោងតាមបញ្ញាតិមាត្រា ៣៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-ប្រាក់ប្រដាប់ក្តី គប្បីតុលាការសម្រេចឱ្យភាគីដើមចោទ ជាអ្នកទទួលបន្ទុកតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-ទទួលស្គាល់លិខិតបញ្ជាក់តាមសំណុំរឿងលេខ ២០១៨ ហូហ្សប់ ៤៥៨ ពាក្យស្នើសុំបញ្ជាក់ការព្រមព្រៀងលែងលះរបស់តុលាការស្រុកដេចន់ ខេត្តឆន់អាន តុលាការក្រុងអាសាន់ស៊ី របស់ប្រទេសកូរ៉េ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] រ័ត្ន ([redacted] ROTH) ជនជាតិខ្មែរ និងឈ្មោះ [redacted] អន់គុន ([redacted] EONGUN) ជនជាតិកូរ៉េ។

២/.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ០៧រោច ខែជេស្ឋ ឆ្នាំជូតទោស័ក ព.ស.២៥៦៤

កណ្តាល,ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

កណ្តាល,ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner